# បច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែ



ជលផលកម្ពុជា



ប្រភពធនធានចំរុះសំរាប់ចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ
អាងភ្ញាស់ត្រី
កន្ទក់ ចុងអង្ករ
រណ្ដៅជីកំប៉ុស
លាមកសត្វ
កាកសំណល់បន្លែ
ម្ទេស
រុក្ខជាតិបៃតង
ត្រប់
ត្រី ស្រូវ

# មាតិកាអត្ថបទ


១-សេចក្ដីផ្ដើម........................................................១

២-ផលប្រយោជន៍នៃការចិញ្ចឹមត្រីក្នុងស្រែ........................................................២

៣-វដ្ដការចិញ្ចឹមត្រី........................................................៣

៤-ទីតាំង និងទំហំស្រែសមស្របសម្រាប់ចិញ្ចឹមត្រី........................................................៣

៥-ការរៀបចំប្រព័ន្ធស្រែចិញ្ចឹមត្រី........................................................៤

៦-កម្រិតទឹកក្នុងស្រែ........................................................១០

៧-ការរៀបចំប្រព័ន្ធប្រឡាយមុនពេលដាក់ត្រីចិញ្ចឹម........................................................១១

៨-ប្រភេទត្រីដាក់ចិញ្ចឹម........................................................១៣

៩-ការដឹកជញ្ជូន និងលែងកូនត្រីចូលប្រឡាយ........................................................១៥

១០-ផ្ដល់ចំណីបន្ថែម និងគ្រប់គ្រង........................................................១៧

១១-ការប្រមូលផល........................................................១៩

# ១. សេចក្តីផ្តើម

ការចញ្ចឹមត្រីនៅក្នុងស្រែត្រូវបានកសិករជាច្រើននៅលើពិភពលោកមានការពេញនិយមចូលចិត្ត បានអនុវត្តន៍ជាយូរណាស់មកហើយ និងបានកំពុងបន្តសកម្មភាពរហូតមកដល់បច្ចុប្បន្ន ជាពិសេសនៅតាមបណ្តាលប្រទេសអាស៊ីអាគ្នេយ៍នេះ។ ដោយឡែក នៅក្នុងប្រទេសកម្ពុជាយើងវិញ ក្រោយការខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់រដ្ឋបាលជលផល ក្នុងការសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាលអង្គការជាតិ និងអន្តជាតិនានាដើម្បីជំរុញការអភិវឌ្ឍន៍លើវិស័យវារីវប្បកម្មពោលគឺចិញ្ចឹមត្រីក្នុងស្រះ បែ និងស៊ងឱ្យការរីកចំរើនយ៉ាងឆាប់រហ័ស បន្ទាប់មកក៏បានបន្តធ្វើការផ្សព្វផ្សាយថែមទៀត លើបច្ចេកទេសចិញ្ចឹមត្រីនៅក្នុងស្រែនៅតាមបណ្តាលខេត្តមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា យើងទទួលបានជោគជ័យប្រកបដោយប្រសិទ្ធភាពខ្ពស់ និងជាទីពេញនិយមរបស់ប្រជាកសិករនាបច្ចុប្បន្នកាលនេះ។ ពីព្រោះថា ការចិញ្ចឹមត្រីក្នុងស្រែបានធ្វើឱ្យកសិករទទួលបាននូវផលប្រយោជន៍ជាច្រើន គឺទទួលបានផលទ្វេដងទាំងស្រូវ និងត្រី ហើយលើសពីនេះទៀត ក្រោយពីដាក់ត្រីចិញ្ចឹមនៅក្នុងស្រែនោះបានធ្វើឱ្យទិន្នផល ស្រូវមានការកើនឡើងខ្ពស់ជាងធម្មតាប្រមាណពី ១០-១៥ ភាគរយ។ ម្យ៉ាងទៀតក៏បានធ្វើឱ្យកសិករភាគច្រើនដែលគ្មានស្រះឬគ្មានបែតែចង់ចិញ្ចឹមត្រីនោះអាចចិញ្ចឹមត្រីបាននៅតាមវាលស្រែរបស់ពួកគាត់ ។

ដោយយល់ឃើញថា នៅមានកសិករជាច្រើននៅក្នុងប្រទេសកម្ពុជាយើងមិនទាន់ បានយល់ដឹងពីបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែនៅឡើយនោះក៏បានធ្វើឱ្យក្រុមការងារបច្ចេកទេស វារីវប្បកម្មយើងខ្ញុំ នៃរដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំព្យាយាមអស់ពីកម្លាំងកាយចិត្តដើម្បី រៀបចំចងក្រងឯកសារបច្ចេកទេសនេះឡើងសម្រាប់ផ្សព្វផ្សាយដល់កសិករផ្សេងៗទៀតដែលចង់ចេះ និងស្វែងយល់បន្ថែមទៀតពីបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែ ជាប្រយោជន៍ជួយធ្វើឱ្យកាន់តែប្រសើរឡើងផ្នែកជីវភាពរស់នៅរបស់កសិករក្រីក្រនៅតាមជនបទនៃព្រះរាជាណាចក្រកម្ពុជាយើង។

## ២. ផលប្រយោជន៍នៃការចិញ្ចឹមត្រីក្នុងស្រែ

អត្ថប្រយោជន៍ជាច្រើនដែលទទួលបានពីការចិញ្ចឹមត្រីក្នុងស្រែរួមមានដូចខាងក្រោមនេះ :

- ☞ កាត់បន្ថយការចំណាយថវិការសម្រាប់ទិញថ្នាំគីមីសម្លាប់សត្វល្អិតចង្រៃ ដោយសារត្រីស៊ីសត្វល្អិតទាំងនោះ
- ☞ មិនចំណាយកម្លាំងពលកម្មសំអាតស្មៅក្នុងស្រែដោយសារត្រីស៊ីស្មៅ ឬរុក្ខជាតិដែលមានផលប៉ះពាល់ដល់ស្រូវ
- ☞ លាមកត្រីជាជីវជាតិដ៏ល្អដល់ការលូតលាស់របស់ស្រូវ
- ☞ នៅពេលដាក់ជីដល់ស្រូវ នោះកាន់តែធ្វើឱ្យសម្បូរថែមទៀតនូវចំណីធម្មជាតិដល់ត្រី
- ☞ ផ្កា និងគ្រាប់ស្រូវដែលជ្រុះទៅក្នុងស្រែគឺជាចំណីរបស់ត្រី
- ☞ ជួយកាត់បន្ថយការចំណាយលើចំណីត្រី
- ☞ ទិន្នផលស្រូវកើនឡើងជាងមុន ( ប្រមាណពី ១០-១៥ ភាគរយ ធៀបជាមួយផលស្រូវមិនបានដាក់ត្រីចិញ្ចឹម) ។
- ☞ កាត់បន្ថយការទិញម្ហូបពីផ្សារ និងបង្កើនចំណូលគ្រួសារ
- ☞ អ្នកដែលគ្មានដីជីកស្រះក៏អាចចិញ្ចឹមត្រីចិញ្ចឹមត្រីបាន

## ៣. រដូវកាលចិញ្ចឹមត្រី

ជាទូទៅប្រទេសកម្ពុជាយើងកសិករចាប់ផ្តើមចិញ្ចឹមត្រីក្នុងស្រែនៅរដូវវស្សា មានភ្លៀងធ្លាក់គ្រប់គ្រាន់ល្មមសមស្របនៅតាមវាលស្រែ។ និយាយជារួម នៅពេលមានពិភពទឹកគ្រប់គ្រាន់ និងអាចលែងកូនត្រីចូលចិញ្ចឹមបាន ក្រោយដែលសន្ទូងបានស្ទូងរួចរយៈពេលពី ១០-១៥ ថ្ងៃ ឬ ជាការប្រសើរបំផុតក្រោយពេលសន្ទូងបែកគុម្ពនៅថ្ងៃទី ២០-២៥ ដើម្បីជៀសវាងកូនត្រីស៊ីពន្លកស្រូវទើបសន្ទូងរួច។

## ៤. ទីតាំង និងទំហំស្រែសមស្របសម្រាប់ចិញ្ចឹមត្រី

### ៤-១ ទីតាំងផ្ទះ

ត្រូវជ្រើសរើសស្រែដែលមានទីតាំងសមស្របដូចខាងក្រោម :

☞ ជិតប្រភពទឹក

☞ ជាប្រភេទស្រែជម្រៅ តែមិនលិចទឹកជំនន់នៅរដូវវស្សា

☞ នៅជិតផ្ទះងាយស្រួលគ្រប់គ្រង។ តែករណីនៅឆ្ងាយវិញ យើងក៏អាចចិញ្ចឹមត្រីបានដែល គ្រាន់តែលំបាក ក្នុងការគ្រប់គ្រងប៉ុណ្ណោះ

☞ ជ្រើសរើសស្រែណាដែលមានគុណភាពដីល្អ ទឹកមិនភ្លាវ មិនជូរ និងមិនសូវជ្រាបទឹក (ដក់ទឹកបានយូរ) ។

### ៤-២ ទំហំផ្ទះ

☞ ទំហំស្រែធំ ឬ តូច វាអនុលោមទៅនិងស្ថានភាពគ្រួសារកសិករនិមួយៗ ដែលអាចមានលទ្ធភាពធ្វើទៅបាន

☞ ទំហំស្រែដែលមានលក្ខណៈសមស្របពី : ១០០០ម² -១០ ០០០ម²

## ៥. ការរៀបចំប្រព័ន្ធស្រែចិញ្ចឹមត្រី

ដើម្បីឱ្យការចិញ្ចឹមត្រីដំណើរការទៅបានល្អ និងទទួលបានទិន្នផលស្រូវកាន់តែខ្ពស់នោះ យើងត្រូវរៀបចំស្រែយ៉ាងណាឱ្យមានប្រព័ន្ធប្រឡាយ ឬស្រះខ្ទុំសមស្របទៅនិងលក្ខណៈជីវសាស្ត្ររបស់ត្រីអាចរស់នៅ និងធំធាត់លូតលាស់បានល្អ ។ ប្រព័ន្ធស្រែចិញ្ចឹមត្រីត្រូវបានរៀបចំដូចខាងក្រោមនេះ :

### ៥-១ លក្ខណៈប្រព័ន្ធស្រែចិញ្ចឹមត្រី

រូបខាងក្រោមនេះជាការរៀបចំប្រព័ន្ធស្រែ ចិញ្ចឹមត្រីតាមគំរូផ្សេងៗគ្នាសម្រាប់កសិករយកទៅអនុវត្តតាមលទ្ធភាពជាក់ស្តែងរបស់កសិករម្នាក់ៗ ។





ភ្លឺស្រែ ភ្លឺប្រឡាយ

ប្រឡាយ ផ្លូវត្រីចេញចូល



ភ្លឺស្រែ ស្រះ

ប្រឡាយ



ភ្លឺស្រែ

ផ្លូវត្រីចេញចូល

ប្រឡាយ

ស្រះ



ភ្លឺស្រែ

ស្រះ

ប្រឡាយ



 ភ្លឺស្រែ

 ផ្លូវត្រីចេញចូល

 ប្រឡាយ

## ៥-២ ភ្លឺស្រែ

ត្រូវរៀបចំភ្លឺស្រែឱ្យមាន :

- ☞ ទំហំទទឹងភ្លឺស្រែ : ២ម
- ☞ កម្ពស់ភ្លឺស្រែពី : 0.៤ -0.៦ម
- ☞ ភ្លឺស្រែត្រូវមានកម្ពស់ខ្ពស់ជាងកម្ពស់ផ្ទៃទឹកក្នុងស្រែដែលខ្ពស់បំផុតពី : ១៥ ស.ម-២0 ស.ម

## អត្ថប្រយោជន៍នៃភ្លឺស្រែ :

- ☞ ការពារត្រីចេញទៅក្រៅស្រែ
- ☞ រក្សាការពារទឹកក្នុងស្រែ
- ☞ នៅលើខ្នងភ្លឺស្រែអាចដាំដំណាំផ្សេងៗ

បានដូចជា: ឪឡឹក បន្លែ ល្ពៅ ម្ទេស និងដំណាំមានប្រយោជន៍ផ្សេងៗទៀត.......។ល។




រូបទី ២ : មុខកាត់ទទឹងប្រព័ន្ធស្រែចិញ្ចឹមត្រី

## ៥-៣ ប្រព័ន្ធប្រឡាយក្នុងស្រែ

☞ ប្រព័ន្ធប្រឡាយគួរឃ្លាតចេញពីភ្លឺស្រែចំងាយ : ០.៥ ម៉ែត្រ ដើម្បីជៀសវាងការបាក់ដីភ្លឺចូលក្នុងឡាយ

☞ រៀបចំប្រព័ន្ធប្រឡាយឱ្យមានទំហំទទឹងមាត់លើពី : ២-៤ មែត្រ

☞ រៀបចំស្ពានបាតប្រព័ន្ធប្រឡាយឱ្យមានទំហំពី : ១-១.៥ ម៉ែត្រ

☞ ជិកជម្រៅប្រព័ន្ធប្រឡាយពី : ០.៨-១.០ ម៉ែត្រ

☞ គួររៀបចំក្រឡាផ្ទៃប្រព័ន្ធប្រឡាយសរុបពី : ១៥ ភាគរយ-២០ ភាគរយនៃក្រឡាផ្ទៃដីស្រែសរុប ។




រូបទី ៣ : ការរៀបចំប្រព័ន្ធប្រឡាយក្នុងស្រែ

## អត្ថប្រយោជន៍នៃប្រព័ន្ធប្រឡាយ

☞ សម្រាប់បំប៉នកូនត្រីៗក្នុងអំឡុងពេលកំពុងភ្ជួររាស់ដីស្រែ និតងកំពុងស្ទូងសន្ទូង ឬទើបស្ទូងសន្ទូងរួច

☞ ជាជម្រកសម្រាប់ត្រីជ្រកកោននៅពេលថ្ងៃក្ដៅ

☞ បង្កលក្ខណៈងាយស្រួលដល់ការប្រមូលផលត្រីនៅពេលសម្រកទឹកពីស្រែ និងធ្វើការច្រូតកាត់ប្រមូលផលស្រូវ



រូបទី ៤ : ការរៀបចំប្រព័ន្ធប្រឡាយក្នុងស្រែ

☞ ព្រមទាំងជាប្រយោជន៍ដល់ការយកទឹកសម្រាប់ស្រោចស្រពដំណាំនៅលើភ្លឺស្រែ ។

## ៥-៤ ទ្វារទឹក

☞ ស្រែនីមួយៗ គួរបង្កើតឱ្យមានទ្វារទឹកចំនួនពី ១-២ កន្លែង សម្រាប់បញ្ចេញបញ្ចូលទឹកនៅពេលមានករណីចាំបាច់ ដូចជា នៅពេលត្រីពុល និងប្រមូលផលត្រីសរុប

☞ ទ្វារទឹកទាំងនោះ អាចធ្វើពីស៊ីម៉ង់ត៍ និងទុយោជ័រ..... ។ល។ ទៅតាមលទ្ធភាពអាចធ្វើបាន ។

## អត្ថប្រយោជន៍នៃទ្វារទឹក

☞ សម្រាប់បើកទឹកបញ្ចូលក្នុងស្រែ

☞ សម្រាប់បញ្ចេញ ឬបញ្ចូលក្នុងស្រែ ពេលករណីចាំបាច់ ដូចជា នៅពេលត្រីពុល ពេលច្រូតកាត់ ប្រមូលផលស្រូវនិងប្រមូលផលត្រីសរុប ដូចជាបានជម្រាបជូនខាងលើ ។

# ៦. កម្រិតទឹកក្នុងស្រែ

☞ គួររក្សាកម្រិតទឹកទាបបំផុតនៅក្នុងប្រឡាយ ០.៨ម ពីព្រោះថា ករណីកម្រិតទឹកទាបជាងនេះអាចបណ្តាលឱ្យត្រីពុល ឬងាប់បាននៅពេលថ្ងៃក្តៅ

☞ កម្រិតទឹកក្នុងស្រែត្រូវបង្កើនបន្ថែមជាបណ្តើរៗឱ្យកាន់តែជ្រៅ ស្របពេលជាមួយនិងការលូតលាស់របស់ស្រូវ និងត្រីកាន់តែធំ

ដូចបានបង្ហាញតាមរយៈ រូបភាពខាងក្រោមនេះ :



រូបទី ៥ : ដំណាក់កាលសន្ទូងទើបស្ទូង



រូបទី ៦ : ដំណាក់កាលសន្ទូងបែកគុម្ព

# ៧. ការរៀបចំប្រព័ន្ធប្រឡាយមុនពេលដាក់ត្រីចិញ្ចឹម

## ៧-១ ការត្រួតពិនិត្យគុណភាពទឹក

គួរធ្វើការត្រួតពិនិត្យគុណភាពទឹកមុនពេលដាក់ត្រីចិញ្ចឹម ព្រោះថាបើករណីគុណភាពទឹកក្នុងស្រែ ឬប្រឡាយមានជាតិជូរឬភ្លាវនោះ យើង មិនអាចធ្វើការចិញ្ចឹមត្រីបានទេ។ ដូចច្នេះ មុនពេលដាក់ត្រីចិញ្ចឹម យើងត្រូវធ្វើការត្រួតពិនិត្យគុណភាពទឹកជាមុនសិន ដូចបានជម្រាបជូននូវវិធីសាស្ត្រសាមញ្ញៗតាមបែបលក្ខណៈគ្រួសារខាងក្រោមនេះ :

☞ ជាបឋម សាកល្បងភ្លក់គុណភាពទឹកក្នុងស្រែ ឬប្រឡាយ បើករណីសង្កេតឃើញថាមានរស់ជាតិជូរ ឬភ្លាវ នោះបញ្ជាក់ថាមិនល្អ

សម្រាប់ចិញ្ចឹមត្រីទេ ។

☞ ម្យ៉ាងទៀត យើងអាចដឹងពីគុណភាពទឹកដោយគ្រាន់តែស្ដោះទឹកមាត់ស៊ីស្លាម្លូទៅលើផ្ទៃទឹក បើសង្កេតឃើញថា នៅតែរក្សាជាពណ៌ក្រហមដដែល នោះបញ្ជាក់ថាគុណភាពទឹកល្អសម្រាប់ចិញ្ចឹមត្រី ។ តែផ្ទុយទៅវិញ ករណី ប្រែពណ៌ពីក្រហមទៅជាពណ៌ខ្មៅនោះបញ្ជាក់ថាទឹកមានជាតិជូរ ឬភ្លាវ ហើយមិនអាចចិញ្ចឹមត្រីបានទេ ។ ករណីនេះហើយយើងចាំបាច់ត្រូវធ្វើការរៀបចំប្រព័ន្ធប្រឡាយឱ្យបានស្អាតល្អជាមុន និងធ្វើការកែប្រែគុណភាពទឹកឱ្យបានល្អគ្មានជាតិជូរ ឬភ្លាវតាមរយៈការប្រើប្រាស់កំបោរ និងជីលាកមសត្វ ជាក្តាសំខាន់ ដូចបានបង្ហាញជូនលំអិតក្នុងចំណុច ៧.២ ខាងក្រោមនេះ :

## ៧ -២ ដំណើការរៀបចំប្រព័ន្ធប្រឡាយ

### ក.ការប្រើប្រាស់កំបោរស

មុនពេលដាក់ត្រីចិញ្ចឹម ១ សប្តាហ៍ យើងត្រូវរៀបចំប្រព័ន្ធប្រឡាយឱ្យបានល្អដើម្បីកំចាត់ចោលនូវរាល់សត្វផ្សេងដែលមានផលប៉ះពាល់ដល់ត្រី និងពពួកមេរោគមួយចំនួនដូចខាងក្រោម :

☞ បូមពង្រីងចេញពីប្រឡាយ រួចបាចកំបោរសនូវកម្រិតបរិមាណពី ១០-១៥ គ.ក្រ ក្នុង១០០ម$^{២}$ ប្រឡាយ ។

☞ បន្ទាប់ពីបាចកំបោរសរួច ត្រូវហាលពន្លឺថ្ងៃរយៈពេលពី ២-៣ ថ្ងៃ

☞ ករណីគុណភាពទឹកមានជាតិជូរនោះធ្វើឱ្យកម្រិត pH ទាបជាង ៥ ដូចច្នេះ យើងត្រូវបង្កើនបន្ថែម បរិមាណកំបោរសទ្វេរដងប្រមាណពី ២០-៣០គ.ក្រ ក្នុង ១០០ម២ ក្រឡាផ្ទៃប្រឡាយ ។

## ៦.  ការប្រើប្រាស់ជីលាមកសត្វ

☞ ជីលាមកសត្វដែលអាចប្រើប្រាស់បានរួមជាមួយ : លាមកសត្វគោ សត្វជ្រូក សត្វមាន់ សត្វទា... ។ល។

☞ ការបាចជីលាមកសត្វជាប្រយោជន៍ដល់ការជួយបន្សាបជាតិជូរផង និងជួយបង្កើនបរិមាណចំណីធម្មជាតិឱ្យកាន់តែច្រើនដល់ត្រីស៊ីខណៈពេលដែលទើបលែងកូនត្រីចូលប្រឡាយដំបូង។

☞ ជីលាមកសត្វត្រូវបានប្រើប្រាស់បន្ទាប់ពីការបាចកំបោររួច។ បរិមាណជីដែលត្រូវប្រើប្រាស់មានពី ២៥-៤០គ.ក្រ ក្នុង ១០០ម$^{២}$ ក្រឡាផ្ទៃប្រឡាយ ដោយបញ្ចូលទឹក ជម្រៅពី ០.១-០.៤ម ហើយ ហាលពន្លឺថ្ងៃរយៈពេលពី ២-៣ ថ្ងៃ ទើបបញ្ចូលទឹកបង្គ្រប់ (ជម្រៅ ០.៨ម ។

## ៨. ប្រភេទត្រីដាក់ចិញ្ចឹម

ជាប្រភេទត្រីដែលមានលក្ខណៈជីវសាស្ត្រសមស្របទៅនិងលក្ខសណ្ឋស្រែ ពោលគឺជាប្រភេទត្រីមានការលូតលាស់លឿន ក្នុងរយៈពេលខ្លី ចន្លោះពីការស្ទូងរួចរហូតដល់ពេលច្រូតកាត់ប្រមូលផលស្រូវ ។ ហើយជាប្រភេទត្រីធន់ទៅនិងលក្ខខណ្ឌ ទឹករាក់នៅក្នុងស្រែព្រមទាំងអាចស៊ីចំណីធម្មជាតិមានស្រាប់នៅ ក្នុងស្រែ ។ លើសពីនេះទៀត ក៏ជាប្រភេទត្រីមានតំលៃសេដ្ឋកិច្ចខ្ពស់នៅលើទីផ្សារផងដែរ ។ ប្រភេទត្រីទាំងនេះរួមមាន : ត្រីទីឡាព្យ៉ា ត្រីឆ្ពិន ត្រីកាបសាមញ្ញ ឬត្រីកាបឥណ្ឌា ត្រីកន្ធរ និងបង្កង... ។ល។



ត្រីទីឡាព្យា



ត្រីឆ្ពិន



ត្រីកាបសាមញ្ញ



ត្រីកន្ធរ



ត្រីកាបឥណ្ឌា



បង្កង

រូបទី ៧ : ប្រភេទត្រីចិញ្ចឹមនៅក្នុងស្រែ

## ៩. ការដឹកជញ្ជូន និងការលែងកូនត្រីចូលប្រឡាយ

### ៩-១ ការដឹកជញ្ជូនកូនត្រី

ជាទូទៅ កូនត្រីពូជត្រូវបានទិញមកពីតាមស្ថានីយ៍រដ្ឋ ឬ កសិដ្ឋានផលិតកូនត្រីពូជឯកជននានាក្នុងតំបន់របស់ខ្លួន ។ ដូចច្នេះកូនត្រីពូជទាំងនោះគួរដឹកជញ្ជូននៅពេលព្រឹក ឬរសៀវមេឃត្រជាក់ ដោយវិធីសាស្ត្រដឹកជញ្ជូនប្រើប្រាស់ថង់កៅស៊ូប្លាស្ទិក និងបញ្ចូលខ្យល់អុកស៊ីសែនដោយបញ្ចូលទឹកចំនួន ១ភាគ ៣ នៃថង់ និងបរិមាណអុកស៊ីសែន ២ ភាគ ៣ នៃថង់ដែលនៅសល់ជាមួយនឹងបរិមាណកូនត្រីពូជប្រមាណពី ២០០-៣០០

ក្បាលក្នុងផង់ ចំពោះកូនត្រីពូជ និង ១០០០-២០០០ ក្បាល ក្នុងផង់ចំពោះកូនត្រីម្យៅ ( ផង់ទំហំ ៦០ ស.ម យ ៨០ ស.ម) រីឯមធ្យោបាយដឹកជញ្ជូនអាស្រ័យដោយ លទ្ធភាពរបស់កសិករម្នាក់ៗដូចជា : រទេះគោ កង់ ម៉ូតូ ឡា ន... ។ល ។

## ៩-២ ពេលវេលាលែងកូនត្រី

ជាទូទៅ យើងអាចលែងកូនត្រីចូលប្រឡាយដើម្បីចិញ្ចឹមបាន នៅពេលដែលទឹកមានពណ៌បៃតង់ខ្ចី និងក្រោយពេលស្ទូងរួចរយៈពេលពី៧-៩ថ្ងៃ ឬ ក្រោយពេលស្ទូងបែកគុម្ពនៅថ្ងៃ ២០-២៥ ដើម្បីជៀសវាងត្រីស៊ីពន្លកស្រូវទើបស្ទូងរួច ។ និយាយរួមយើងអាចកំណត់ពេលវេលាលែងកូនត្រីបានច្បាស់លាស់អាស្រ័យដោយ :

- មានទឹកគ្រប់គ្រាន់
- ប្រភពកូនត្រីពូជអាចរកទិញបាននៅក្នុងតំបន់របស់ខ្លួន
- លទ្ធភាពរបស់កសិករម្នាក់ៗអាចធ្វើទៅបានជាពេលវេលាសមស្របរបស់ខ្លួន ។

## ៩-៣ ការលែងកូនត្រីពូជចូលប្រព័ន្ធប្រឡាយ

ក្រោយពេលដឹកជញ្ជូន មិនគួរលែងកូនត្រីពូជចូលប្រឡាយ ឬស្រែ ភ្លាមៗនោះទេ ជៀសវាងត្រីពុល ឬអាចងាប់ ។ ដូចច្នេះ គួររក្សា កូនត្រីពូជនៅកន្លែងណាដែលត្រជាក់មួយរយៈពេលខ្លីជាមុនសិន បន្ទាប់មកធ្វើការលែងដោយសន្សឹមៗរយៈពេលពី ១៥-២០ នាទី ដើម្បីជាប្រយោជន៍ដល់កូនត្រីមានការបន្សាំទៅនឹងមជ្ឈដ្ឋានទឹកថ្មីនៅក្នុងប្រឡាយ ស្រះ ឬស្រែ ។




រូបទី ៨ : សកម្មភាពលែងកូនត្រីចូលប្រឡាយ

## ៩-៤ ចំនួនកូនត្រីដាក់ចិញ្ចឹម

ចំនួនកូនត្រីដែលត្រូវដាក់ចិញ្ចឹមនៅក្នុងប្រព័ន្ធស្រែក៏ដូចជានៅក្នុងស្រះ គឺជាកត្តាមួយដ៏សំខាន់ដែលទាក់ទងទៅនឹងដំណើរជីវិតរស់នៅរបស់ត្រីដូចជាកត្តាគុណភាពទឹក ចំណីធម្មជាតិ និងការលូតលាស់ធំធាត់។ ដូចបានជម្រាបជូន នៅខាងដើមរួចមកហើយថា ត្រីសម្រាប់ចិញ្ចឹមនៅក្នុងស្រែជាប្រភេទត្រីដែលមានចរិតស៊ីចំណីធម្មជាតិមានស្រាប់នៅក្នុងស្រែដែលប្រភេទទាំងនោះរួមមានដូចជា : ត្រីទីឡាព្យ៉ា ត្រីកាបសាមញ្ញ ត្រីឆ្ពិន ត្រីកាបឥណ្ឌា និងបង្កង...។ល។ ហើយប្រភេទត្រីទាំងនេះអាចដាក់ចិញ្ចឹមបាននៅក្នុងចន្លោះពី ១-២ក្បាលក្នុងមួយម៉ែត្រការេក្រឡាផ្ទៃសរុបទាំងស្រែ និងប្រឡាយ ។

តាមរយៈលទ្ធផលទទួលបានពីការអនុវត្តជាក់ស្តែងនៅតាមបណ្តាលប្រទេសជិតខាង ក៏ដូចជានៅប្រទេសកម្ពុជា យើងឃើញថាប្រភេទត្រីទាំងនេះត្រូវបានគេដាក់ចិញ្ចឹមជាលក្ខណៈចម្រុះគ្នាដោយបែងចែកជាភាគរយ អាស្រ័យប្រភេទត្រីនីមួយៗ ដូចបានបង្ហាញជូនខាងក្រោម :

☞ ត្រីទីឡាព្យាមានទំហំពី ៤-៦ ស.ម (២០-៣០ ភាគរយ)

☞ ត្រីឆ្ពិនមានទំហំពីៈ ៤-៦ ស.ម (៤០-៥០ ភាគរយ)

☞ ត្រីកន្ធរ ឬបង្កងមានទំហំពីៈ ៣-៥ ស.ម (៥-១០ ភាគរយ)

☞ ត្រីកាបសាមញ្ញមានទំហំពីៈ ៦-៨ ស.ម ឬ ត្រីកាបឥណ្ឌា ទំហំពី : ៦-៨ ស.ម (១០-២០ ភាគរយ)

| ល.រ | ប្រភេទត្រី | ទំហំកូនត្រី (ស.ម) | ភាគរយត្រីដាក់ចិញ្ចឹម(ភាគរយ) | ចំនួនកូនត្រីដាក់ចិញ្ចឹម(ក្បាល/ម$^{២}$) |
|---|---|---|---|---|
| ១ | ត្រីទីឡាព្យា | ៤-៦ | ២០-៤០ | ១ ទៅ ២ |
| ២ | ត្រីឆ្ពិន | ៤-៦ | ៤០-៥០ | |
| ៣ | ត្រីកន្ធរ ឬបង្កង | ៣-៥ | ៥-១០ | |
| ៤ | កាបសាមញ្ញ ឬកាបឥណ្ឌា | ៦-៨ | ១០-២០ | |

## ១០. ការផ្តល់ចំណីបន្ថែម និងគ្រប់គ្រង

### ១០-១ ការផ្តល់ចំណី

● **ចំពោះប្រភេទត្រីស៊ីចំណីធម្មជាតិចម្រុះ:** ត្រូវដាក់ជីលាមកសត្វបន្ថែមជាប្រចាំនៅក្នុងប្រព័ន្ធប្រឡាយ បើករណីសង្កេតឃើញថា ទឹកប្រែប្រួលគុណភាពពីពណ៌ថ្លាបៃតងខ្ចីទៅជាល្អក់។ ការដាក់ជីលាមកសត្វបន្ថែមនេះគឺដើម្បីបង្កើនចំណីធម្មជាតិសម្រាប់ឱ្យត្រីស៊ី។ បរិមាណជីដែលត្រូវប្រើប្រមាណពី ១០-១៥ គ.ក្រ ក្នុង១០០ម$^{២}$ ក្រឡាផ្ទៃស្រែ និងប្រឡាយសរុប។ ក្រៅពីនេះ យើងអាចផ្តល់ចំណីបន្ថែមបានដូចជាកន្ទក់ ចុងអង្ករ ដំឡូងមី និង ស្លឹកត្រកួន...។ល។

● **ចំពោះប្រភេទត្រីស៊ីរុក្ខជាតិ:** គួរផ្តល់ចំណីបន្ថែមឱ្យត្រីស៊ីជារៀងរាល់ថ្ងៃ។ សមាធាតុចំណីសំខាន់ៗផ្សំពីពពួកបន្លែផ្សេងៗ ដូចជា ស្លឹកត្រកួន ស្លឹកស្ពៃ និងសាឡាត់...។ល។ បរិមាណចំណីដែលត្រូវឱ្យត្រីស៊ីប្រមាណពី ២០-២៥ គ.ក្រ សម្រាប់ត្រីទំងន់សរុប ១០០ គ.ក្រ

ដោយផ្តល់ឱ្យត្រីស៊ីចំនួន ០២ ដងក្នុងមួយថ្ងៃគឺនៅពេលព្រឹក និងពេលល្ងាច។ ក្រៅពីនេះ ក៏យើងអាចផ្តល់ចំណីបន្ថែមផ្សេងៗទៀតបានដែរ ដែលមានស្រាប់នៅតាមមូលដ្ឋានរបស់កសិកររួមមានដូចជា កន្ទក់ ចុងអង្ករ កាកសណ្តែកសៀង និងកាកសំណល់ផ្ទះបាយនូវបរិមាណ ១ គ.ក្រ ចំណីសម្រាប់ត្រីទម្ងន់សរុប ១០០ ក្នុងមួយថ្ងៃ ។



ការឱ្យចំណីជន្លេន



ការឱ្យចំណីកាកសំណល់បន្លែ



ការឱ្យចំណីកន្ទក់

## ១០-២ ការគ្រប់គ្រង

- ជារៀងរាល់ថ្ងៃត្រូវឧស្សាហ៍ព្យាយាមដើរត្រួតពិនិត្យជាប្រចាំ នូវរាល់ ទ្វារបញ្ចូលទឹក និងភ្លឺស្រែ ដើម្បីជៀសវាងការបាក់ធ្លុះធ្លាយ ។
- ក្រោយពេលស្ទូងសន្ទូងរួចរយៈពេលពី ១០-១៥ ថ្ងៃ ឬជាការប្រសើរបំផុតក្រោយពេលសន្ទូងបែកគុម្ពនៅថ្ងៃទី ៥២០-២៥ ត្រូវបញ្ចូលទឹកបន្ថែមចូលស្រែដោយសន្សឹមៗដើម្បីឱ្យត្រីអាចចូលទៅក្នុងស្រែរកចំណីស៊ីបាន។
- នៅពេលស្រូវបែកគុម្ពកាន់តែធំ បើអាចគួរដកស្រូវចេញខ្លះ ដើម្បីធ្វើឱ្យមានចន្លោះ ២០ ស.ម ឬ ២ តឹក ផ្តល់ភាពងាយស្រួលដល់ត្រីហែល

រកចំណីស៊ីនៅក្នុងស្រែ ។

- ករណីសង្កេតឃើញត្រីងើបក្បាលច្រើននៅលើផ្ទៃទឹកពេលព្រឹកព្រលឹមជាញឹកញាប់នោះត្រូវផ្លាស់ប្តូរទឹកថ្មីប្រមាណពី ២០-៣០ភាគរយ
- ត្រូវរក្សាជម្រៅទឹកនៅក្នុងស្រែពី ២០-៣០ ស.ម ឬ ពី២-៣ តឹក ជានិច្ច ។

## ១១. ការប្រមូលផល

ជាទូទៅ យើងធ្វើការប្រមូលផលត្រីនៅរដូវប្រាំង ឬក្រោយពេលច្រូតកាត់ស្រូវរួច និងធ្វើងឡើងស្របជាមួយនឹងតម្លៃត្រីនៅលើទីផ្សារមានការកើនឡើងខ្ពស់ ។ វិធីសាស្ត្រប្រមូលផលត្រីត្រូវបានគេអនុវត្តដូចខាងក្រោមនេះ :

☞ ក្រោយពេលចិញ្ចឹមបានរយៈពេលពី ២-៣ ខែ យើងអាចចាប់ផ្តើមប្រមូលផលរំលួសជាបណ្តើរៗ ដោយប្រើ សំណាញ់ មង និងអួសអួន ចាប់យកត្រីដែលធំៗ និងរក្សាទុកត្រីតូចៗដើម្បីចិញ្ចឹមបន្ត ។

☞ ប្រមូលផលត្រីសរុប ដោយបូមទឹកសម្រកពីក្នុងស្រែ ដើម្បីប្រមូលផលត្រីចូលទៅក្នុងប្រឡាយរួចប្រើប្រាស់ អួនសម្រាប់អូសប្រមូលផលត្រី ។

☞ ការប្រមូលផលត្រីសរុបចុងក្រោយនេះ ក៏យើងអាចប្រមូលតែត្រីធំៗ និងរក្សាទុកត្រីតូចៗ ដើម្បីចិញ្ចឹមបន្តនៅក្នុងស្រះឬប្រឡាយនិងនៅកន្លែងផ្សេងៗទៀត ។

# គន្លឹះសំខាន់ៗមួយចំនួនសម្រាប់ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ

- ការសំអាតស្រះមុនពេលដាក់ត្រីចិញ្ចឹម ជាកត្តាសំខាន់ណាស់ ធ្វើឱ្យការចិញ្ចឹមត្រីរបស់អ្នកទទួលជោគជ័យ
- បើមានត្រីផ្ទក់ ឬ ត្រីរស់តែមួយនៅក្នុងស្រះ វានឹងស៊ីកូនត្រីដែលអ្នកដាក់ចិញ្ចឹមអស់ក្នុងរយៈពេលយ៉ាងខ្លី
- ការដាក់ជីជាប្រចាំដើម្បីឱ្យទឹកស្រះមានពណ៌បៃតង ជាកត្តាសំខាន់ណាស់ ធ្វើឱ្យត្រីរបស់អ្នកធំធាត់ល្អ
- ពន្លឺថ្ងៃជាកត្តាសំខាន់មួយធ្វើអោយចំណីធម្មជាតិ ឬ ប្លង់តុងកើតក្នុងស្រះបានល្អក្រោយពេលដាក់ជី
- ការចិញ្ចឹមត្រីក្នុងស្រះមានប្រឡាយភ្ជាប់ទៅស្រែ ជាវិធីមួយដ៏ល្អ ជួយអោយត្រីរបស់អ្នកធំធាត់ឆាប់រហ័ស
- ហើយអ្នកអាចបន្ថយការចំណាយលើការផ្តល់ចំណីទៀតផង ។

## រូបមន្តសំខាន់ៗដែលអ្នកគួរចងចាំ សម្រាប់ការចិញ្ចឹមត្រី

**ផ្ទៃក្រឡាស្រះជាម៉ែត្រការ៉េ = ប្រវែងបណ្តោយស្រះជាម៉ែត្រ X ប្រវែងទទឹងស្រះជាម៉ែត្រ**

ឧទាហរណ៍: ស្រះមានប្រវែងបណ្តោយ ១៥ម និងទទឹង ១០ម ។ ផ្ទៃក្រឡាស្រះ = ១៥ម X ១០ម = ១៥០ ម$^{២}$

**មរិមាណកំបោរប្រើប្រាស់ក្នុងស្រះ = ផ្ទៃក្រឡាស្រះជាម៉ែត្រការ៉េ X $\frac{\text{បរិមាណកំបោរប្រើក្នុងមួយរយម៉ែត្រការ៉េ}}{\text{១០០}}$**

ឧទាហរណ៍: ស្រះមានផ្ទៃក្រឡា ១៥០ម$^{២}$ ចង់ប្រើកំបោរ ១០គក្រ ក្នុង ១០០ម$^{២}$ ។ បរិមាណកំបោរប្រើប្រាស់ក្នុងស្រះ = ១៥០ X $\frac{\text{១០}}{\text{១០០}}$ = ១៥ គក្រ

**ចំនួនកូនត្រីដាក់ចិញ្ចឹមក្នុងស្រះ= ផ្ទៃក្រឡាស្រះជាម៉ែត្រការ៉េ X ចំនួនកូនត្រីដាក់ចិញ្ចឹមក្នុង ១ម$^{២}$**

ឧទាហរណ៍: ស្រះមានផ្ទៃក្រឡា ១៥០ម$^{២}$ ចង់ដាក់ត្រីចិញ្ចឹម ៣ក្បាល ក្នុង១ម$^{២}$ ។ ចំនួនកូនត្រីដាក់ចិញ្ចឹម = ១៥០ X ៣ = ៤៥០ ក្បាល

**មរិមាណជីអ៊ុយរ៉េប្រើប្រាស់ក្នុងស្រះ = ផ្ទៃក្រឡាស្រះជាម៉ែត្រការ៉េ X $\frac{\text{បរិមាណជីអ៊ុយរ៉េប្រើក្នុងមួយរយម៉ែត្រការ៉េ}}{\text{១០០}}$**

ឧទាហរណ៍: ស្រះមានផ្ទៃក្រឡា ១៥០ម$^{២}$ ចង់ប្រើជីអ៊ុយរ៉េ ៤ខាំ ក្នុង ១០០ម$^{២}$ ។ បរិមាណជីអ៊ុយរ៉េប្រើប្រាស់ក្នុងស្រះ = ១៥០ X $\frac{\text{៤}}{\text{១០០}}$ = ៦ខាំ

រៀបរៀងដោយ : នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល

ឧបត្ថម្ភបោះពុម្ពដោយ : Project Code: 10-PR1-0409

MINISTERIO DE ASUNTOS EXTERIORES Y DE COOPERACIÓN

aecid

AIDA
AYUDA, INTERCAMBIO Y DESARROLLO

ព័ត៌មានបន្ថែមសូមទំនាក់ទំនងនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល
អគារលេខ ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៨៣៥ ទូរស័ព្ទ/ទូរសារ ៨៥៥ ២៣ ៩៩៦ ៣៨០
អ៊ីមែល : chinda77@yahoo.com